# ឱសថការីបសុពេទ្យ

## តើអ្នកអាចជួយដោះបញ្ហាស្រាយភាពស៊ាំនឹងឱសថប្រឆាំងមេរោគនៅកម្ពុជាដោយរបៀបណា ?




### តើអ្វីទៅជាភាពស៊ាំនឹងថ្នាំប្រឆាំងនឹងមេរោគ (AMR) ?

- AMR កើតឡើងនៅពេលដែលឱសថអង់ទីប៊ីយ៉ូទិកលែងមានប្រសិទ្ធភាព ក្នុងការព្យាបាលជំងឺបាក់តេរីដែលកើតលើមនុស្ស និងសត្វ
- ការប្រើប្រាស់ឱសថអង់ទីប៊ីយ៉ូទិកមិនត្រឹមត្រូវ និងហួសកម្រិត បង្កឱ្យមានការវិវត្តនៃ AMR កាន់តែលឿន
- AMR មានការរីករាលដាលយ៉ាងទូលំទូលាយនៅក្នុងប្រទេសកម្ពុជា
- វាមានសារៈសំខាន់ណាស់ក្នុងការថែរក្សាប្រសិទ្ធភាព និងលទ្ធភាពទទួលបានឱសថអង់ទីប៊ីយ៉ូទិកសម្រាប់ការព្យាបាលប្រកបដោយប្រសិទ្ធភាពលើជំងឺឆ្លង

អ្នកអាចជួយកាត់បន្ថយភាពស៊ាំឱសថប្រឆាំងមេរោគដោយ៖

- ធានាថាបុគ្គលិកធ្វើការត្រូវបានបណ្តុះបណ្តាលគ្រប់គ្រាន់ក្នុងការប្រើប្រាស់ឱសថអង់ទីប៊ីយ៉ូទិក
- ត្រូវប្រើប្រាស់តែឱសថអង់ទីប៊ីយ៉ូទិកដែលបានចុះបញ្ជី ឬឱសថដែលចែកចាយមកពីប្រភពដែលមានការអនុញ្ញាតច្បាស់លាស់
- ការរក្សាទុកឱសថអង់ទីប៊ីយ៉ូទិកឱ្យបានត្រឹមត្រូវតាមការណែនាំរបស់អ្នកផលិត
- លក់ឱសថអង់ទីប៊ីយ៉ូទិកដោយយោងទៅតាមវេជ្ជបញ្ជាចេញដោយបសុពេទ្យមានសមត្ថកិច្ច
- រក្សាកំណត់ត្រាត្រឹមត្រូវនៃឱសថអង់ទីប៊ីយ៉ូទិកដែលបានលក់
- ការចែករំលែកទិន្នន័យស្តីពីឱសថអង់ទីប៊ីយ៉ូទិកដែលបានលក់ជាមួយនិយតកររដ្ឋាភិបាល
- បោះចោលដោយសុវត្ថិភាពនូវឱសថអង់ទីប៊ីយ៉ូទិកដែលមិនប្រើ ឬផុតកំណត់ រាប់បញ្ចូលទាំងដបឬសម្បកររបស់វាផងដែរ។

**អ្នកអាចជួយកាត់បន្ថយភាពស៊ាំឱសថប្រឆាំងមេរោគ ក្នុងប្រទេសកម្ពុជា តាមរយៈការលក់ឱសថអង់ទីប៊ីយ៉ូទិកដោយ ទំនួលខុសត្រូវ**

ផលិតដោយអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ ជាមួយការគាំទ្រនៃអង្គការសុខភាពសត្វពិភពលោក និងការចូលរួមថវិការបស់គម្រោង
AMR Multi-Partner Trust Fund

World Organisation for Animal Health
Founded as OIE